ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថបទស្រាវជ្រាវ

# រដ្ឋបាល

# និង

# រដ្ឋបាលវិមជ្ឈការ

ឯកសារជំនួយស្មារតី

Shared by page: Mr. That Chantha
https://www.facebook.com/thatchantha

# រដ្ឋបាល និង រដ្ឋបាលវិមជ្ឈការ

*("Administration and Decentralization Administration")*

មេរៀននេះ មានគោលបំណងអោយនិស្សិត យល់ពីប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលកម្ពុជា ជាពិសេស នយោបាយវិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជាយើង ។ អោយនិស្សិតយល់ពី តួនាទីរបស់អំណាចកណ្តាល និង អំណាចមូលដ្ឋាន នៅក្នុងការគ្រប់គ្រងរដ្ឋបាល និង ការបម្រើសេវាកម្មសាធារណៈ ដល់ប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសប្រយោជន៍ទូទៅរបស់ជាតិ ។ លក្ខន្តិកៈគតិយុត្ត ឬ ទំរង់របស់រដ្ឋ មានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការរៀបចំអំណាចរដ្ឋបាល (Administrative Power ) របស់រដ្ឋនីមួយៗ ។ ប្រទេសកម្ពុជាយើងជារដ្ឋទោល (Unilateral State/ Etat Unitaire) និង ជារាជាណាចក្រមួយដែលមិនអាចបំបែកបាន[1] ប្រការនេះវាមានផល វិបាកលើការរៀបចំ អំណាចរដ្ឋបាល ។ ក្នុងប្រទេសយេងី ដែលជារដ្ឋទោលវាមានការ ខុសគ្នាជាមួយ រដ្ឋសហព័ន្ធនៅក្នុងរដ្ឋទោល រដ្ឋគ្មានដៃគូប្រជែងឡើយ គឺអំណាចទាំងអស់ត្រូវស្ថិតក្នុងកណ្តាប់ដៃរបស់រដ្ឋ (អំណាចចេញបទបញ្ញាទូទៅ = General Regulation Power/ Pouvoir reglementaire generalជាអំណាចផ្តាច់មុខរបស់រដ្ឋបាលកណ្តាល)។ ក្នុងការគ្រប់គ្រងរដ្ឋបាលមិនតំរូវអោយគេត្រូវតែប្រកាន់យកប្រព័ន្ធ រដ្ឋបាលមជ្ឈការ (Centra lisation) ជាដាច់ខាតនោះទេ គេអាចធ្វើវិមជ្ឈការរដ្ឋបាល (decentralization administratif) ដោយ មិនធ្វើអោយប៉ះពាល់ដល់ឯកភាពនយោបាយរបស់រដ្ឋ។ ការបែងចែក អំណាចរដ្ឋបាល ( The separation of Administrative Power/ La repartition du pouvoir administratif) អាចធ្វើឡើងក្រោមរូបភាពដូចតទៅ ៖

- មជ្ឈការ = La centralisation/The centralization
- វិសហមជ្ឈការ = La deconcentration/The deconcentration
- វិមជ្ឈការ = La decentralisation/The decentrilisation

សព្វថ្ងៃ ប្រទេសបារាំង អនុវត្តប្រពន្ធ័ទាំងបីនេះជាមួយគ្នាតែម្តង ។ រីឯប្រទេសខ្មែរយើងវិញ បើយោលទៅតាមកម្មវិធីនៃការកែទំរង់ប្រព័ន្ធរដ្ឋបាល និង វិមជ្ឈការថ្នាក់ ឃុំ/សង្កាត់ដែលបានធ្វើនៅឆ្នាំ ២០០២ នេះទៅ ថ្ងៃអនាគត ប្រទេសយើងនិងអនុវត្តប្រព័ន្ធទាំងបីនេះជាមួយគ្នាដែរ ។

[1] មាត្រា ៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

## ១. អំពីមជ្ឈការ (Centralisation )

### ក. មជ្ឈការ និង អំណាចកណ្តាល

មុនដំបូងយើងគួរយល់ន័យនូវអ្វីដែលគេហៅថា "អំណាចកណ្តាល" (les autoirites centrales) "អំណាចកណ្តាល" គឺអំណាចរដ្ឋាភិបាល ដែលកាន់កាប់ដោយនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នរដ្ឋទាំងឡាយ ។ "មជ្ឈការ" ជាប្រព័ន្ធរដ្ឋបាលមួយដែលនៅក្នុងនោះ អំណាចសម្រេចសេចក្តី និង បញ្ជា ចេញពី "អំណាចកណ្តាល" ទាំងអស់ ហើយត្រូវអនុវត្តន៍ ដោយភ្នាក់ងាររដ្ឋគ្រប់ជាន់ថ្នាក់ដោយផ្ទាល់ ។ "អំណាចកណ្តាល" ជាតំណាងនៃរដ្ឋ ។

ប្រព័ន្ធមជ្ឈការមានគោលការណ៍ចំបងដូចតទៅ ៖

- នីតិបុគ្គលសាធារៈមានតែមួយ ។
- អំណាចសំរេចសេចក្តី និង បញ្ជា ប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល ។
- រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមគោលការណ៍ឋានានុក្រម (Hierarchisation de l′ administration) ដែលស្ថិតនៅក្រោមចំណុះ និង ការត្រួតពិនិត្យផ្ទាល់របស់អំណាចកណ្តាល ឬរដ្ឋបាលកណ្តាល ។

ភ្នាក់ងាររបស់រដ្ឋគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលមានទីតាំងនៅមូលដ្ឋាននានា បំពេញនាទីជាអ្នក ប្រើប្រាស់អំណាចរដ្ឋបាល ហើយត្រូវស្ថិតនៅក្រោមអំណាចឋានានុក្រមរបស់អំណាចកណ្តាល ។ ភ្នាក់ ងារទាំងនោះទទួលបញ្ជាផ្ទាល់ពីរដ្ឋបាលកណ្តាល និង ទទួលបន្ទុកអនុវត្តន៍បញ្ជាទាំងនេះ សិទ្ធិចំពោះ គំនិតផ្តួចផ្តើមរបស់វាក៏មានកម្រិតដែរ ។ ប្រវត្តិរដ្ឋបាលនៅប្រទេសកម្ពុជា បានបង្ហាញអោយឃើញពីការស្ថាបនាឡើងនូវរដ្ឋមជ្ឈការមួយ ។ តាំងពីយូរយារណាស់មកហើយ មជ្ឈការរដ្ឋបាលត្រូវបានគេចាត់ទុកថាជាសារជាតុដ៏សំខាន់របស់ មជ្ឈការនយោបាយ ។ ការអនុវត្តន៍ប្រព័ន្ធមជ្ឈការជាលក្ខណៈនៃរដ្ឋបាលប្រទេសខ្មែរដែលទទួលឥទ្ធិពល របស់ប្រព័ន្ធរដ្ឋបាលបារាំង ។ ប្រព័ន្ធមជ្ឈការជាមូលដ្ឋានមួយសំរាប់ស្វែងយល់ពីសង្គមខ្មែរយើងអាចធ្វើការ កំនត់សំគាល់បានដោយងាយអំពីបញ្ហានេះ តាមរយៈសារៈសំខាន់នៃរាជធានីភ្នំពេញប្រើប្រៀបធៀប និង បណ្តាខេត្តនានាភ្នំពេញមិនមែនគ្រាន់ជាមជ្ឈមណ្ឌលរបស់រដ្ឋបាលប៉ុណ្ណោះទេ ។ តែវាជា

ទីតាំងរបស់ស្ថាប័នរដ្ឋធំៗ សហគ្រាសធំៗ អង្គភាពអន្តរជាតិ នានា សមាគមផ្សេងៗ ប៉ុស្តិ៍ទូរទស្សន៍ វិទ្យុជាតិ និង ឯកជនផងដែរ ។

### ខ. គុណសម្បត្តិនៃមជ្ឈការ

- ធ្វើអោយរដ្ឋការសំរេចអ្វីមួយ ដូចៗគ្នាទូទាំងប្រទេស គឺនាំឱ្យមានឯកភាពទាំងខាងទស្សនៈ ទាំងខាងអំពើរបស់រាជការផង ហើយម៉្យាងទៀត ឯកភាពនៃប្រទេសក៏មានភាពរឹងមាំល្អពីព្រោះរដ្ឋក្តាប់ស្ថានការណ៍ទាំងអស់បាន ។

- ភ្នាក់ងារដែលត្រូវបានតែងតាំង សំរាប់ថ្នាក់ដឹកនាំរដ្ឋបាលមូលដ្ឋាន អាចជាអ្នកមានសមត្ថភាព ។

### គ. គុណវិបត្តិនៃរបបមជ្ឈការ

- ការធ្វើមជ្ឈការដែលប្រមូលផ្តុំរឿងទាំងអស់នេះមកថ្នាក់លើតែមួយ បណ្តាលឱ្យអង្គការនៃ អំណាចកណ្តាលលិចលង់ទៅដោយសំនុំរឿងទាំងនោះ។ កិច្ចការកកកុញស្ទះមិនចេញ នាំឱ្យមានការ យឺតយ៉ាវក្នុងការងារ និងមិនឆ្លើយតបតាមតំរូវការចាំបាច់ ។

- រដ្ឋការអាចមិនដឹងពីសេចក្តីត្រូវការពិតប្រាកដរបស់ប្រជារាស្ត្រ នៅតាមទីកន្លែងឱ្យបានសព្វ គ្រប់ឡើយប្រការនេះនាំអោយសេចក្តីសំរេច ឬ កម្មវិធីនយោបាយដែលចេញដោយអំណាចកណ្តាលពុំសូវ មានប្រសិទ្ធភាព និង មិនអាចឆ្លើយតបនឹងតំរូវការរបស់ប្រជារាស្ត្រនៅមូលដ្ឋាន ។

- ប្រជារាស្ត្រជួបការលំបាក ក្នុងជីវភាពប្រចាំថ្ងៃ ព្រោះពួកគេឡើងមករាជធានីដើម្បីធ្វើកិច្ចការ ចាប់តាំងពីការងារតូចតាចឡើងទៅ ។

ប្រព័ន្ធមួយមជ្ឈការខ្លាំងពេកមិនអាចយកមកអនុវត្តបានទេនៅក្នុងរដ្ឋសម័យទំនើប ។ ដូច្នេះគេ ត្រូវតែកែសម្រួលប្រព័ន្ធមជ្ឈការ គេច្រើនធ្វើការរំលែកអំណាចកណ្តាលខ្លះ (វិសហមជ្ឈការ = deconcen tration) ឱ្យទៅភ្នាក់ងាររដ្ឋជាន់ខ្ពស់ ដែលនៅនឹងទីកន្លែងផ្ទាល់ជាមួយរាស្ត្រ ។ នេះជាវិធានមួយដែល ធ្វើឱ្យរដ្ឋការបាននៅក្បែរជិតរាស្ត្រ ប៉ុន្តែរាស្ត្រគ្មានសិទ្ធិចូលរួមធ្វើសេចក្តីសំរេច ជាមួយរដ្ឋការទេរដ្ឋការជា អ្នកសំរេច ។

## ២. វិសហមជ្ឈការ (Deconcentration)

សញ្ញាណ ៖ វិសហមជ្ឈការ ជាបច្ចេកទេសនៃការរៀប ចំរដ្ឋបាលមួយ ដែលត្រូវបង្កើតឡើង ដើម្បីកែសំរួលដល់ប្រព័ន្ធមជ្ឈការ ហើយដែលបានផ្តល់ទៅអោយអាជ្ញាធរដែនដីនូវអំណាច សម្រេចសេចក្តីលើកិច្ចការខ្លះៗ ដែលជាធម្មតាអំណាចទាំងនេះ ជារបស់រដ្ឋបាលកណ្តាលភ្នាក់ ងារដែលទទួលបន្ទុកដឹកនាំអាជ្ញាធរដែនដីទាំងនេះ ត្រូវស្ថិតនៅក្រោមអំណាចឋានានុក្រមនៃ រដ្ឋបាលកណ្តាលដដែលគេមិនត្រូវច្រឡំវិសហមជ្ឈការជាមួយការឡើយ ព្រោះវិសហមជ្ឈការ មិនបានធ្វើឱ្យមានការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលឡើយ វាគ្រាន់តែសំរួលដល់ ប្រព័ន្ធមជ្ឈការ ប៉ុណ្ណោះ។

វិសហមជ្ឈការផ្តល់នូវភាពទន់ភ្លន់ដល់ដំណើរការរដ្ឋបាល និង ភាពធូរស្រាលដល់ អំណាចកណ្តាលព្រោះវាបានផ្តល់នូវការទទួលខុសត្រូវចំពោះកិច្ចការខ្លះៗ ដល់អាជ្ញាធរដែនដី ដើម្បីសំរេចកិច្ចការក្នុងនាមអំណាចកណ្តាល ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ នៅប្រទេសបារាំង ៖ វិសហមជ្ឈការត្រូវបានឱ្យតំលៃយ៉ាងខ្ពស់លើប្រសិទ្ធភាពរបស់ វាក្លាយជាអាទិភាពមួយ ក្នុងចំណោមអាទិភាពនៃនយោបាយកំណែ ទម្រង់រដ្ឋ ។[2] យោងតាមអត្ថបទ ទាំងពីរនេះ របបវិមជ្ឈការមានគោលការណ៍ធ្វើការបែងចែកអំណាចកណ្តាល និង រដ្ឋបាល ដែនដី ដូចតទៅ ៖

- រដ្ឋបាលកណ្តាលជាអ្នកកំណត់ទិសដៅ និង នយោបាយជាមូលដ្ឋានតាមរយៈច្បាប់ និង បទបញ្ជា
- រដ្ឋបាលដែនដី ទទួលបន្ទុកអនុវត្តនយោបាយទាំងនេះ នៅតាមមូលដ្ឋានរៀងខ្លួន ។
- រៀបចំឱ្យបានល្អប្រសើរ នូវដំណើរការរដ្ឋបាលវិសហមជ្ឈការទូទាំងប្រទេស ។

ក្នុងរបបវិសហមជ្ឈការ ការដែលអំណាចកណ្តាលរំលែកអំណាចខ្លះ ទៅឱ្យរដ្ឋបាលដែនដី មិន មែនបានន័យថាប្រគល់សិទ្ធិឱ្យសំរេចអ្វីដោយស្វ័យភាពទេ ។ ផ្ទុយទៅវិញ គឺជាការប្រគល់សិទ្ធិឱ្យ សរំេចក្នុងនាមរដ្ឋ ដោយមានចែងលក្ខខណ្ឌយ៉ាងច្បាស់លាស់ ជាលាយលក្ខណអក្សរកំណត់ ព្រំដែននៃសិទ្ធិនោះផង ។ លិខិតនេះគេហៅថា "ប្រតិភូកម្មនៃអំណាច" (delegation de pouvoir) ។ "ប្រតិភូកម្មនៃអំណាចនេះ" ត្រូវធ្វើឡើងដោយអាជ្ញាធរអំណាចកណ្តាល ទៅឱ្យអាជ្ញាធរ ថ្នាក់ក្រោមដែលពេលនោះនឹងមានសិទ្ធិសំរេច

[2] នៅប្រទេសបារាំង មានអត្ថបទច្បាប់មួយចំនួន ដែលជាមូលដ្ឋាននៃវិសហមជ្ឈការ ច្បាប់ចុះថ្ងៃទី ៦ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីរដ្ឋបាលដែនដីរបស់សាធារណៈរដ្ឋបារាំង និង ក្រឹត្យ ចុះថ្ងៃទី ១ កក្កដា ឆ្នាំ ១៩៩២ ស្តីពី ធម្មនុញ្ញនៃវិសហមជ្ឈការ។

ផ្ទាល់បាន ប៉ុន្តែក្នុងនាមអាជ្ញាធរកណ្តាល ដដែល ។ ឧទាហរណ៍សកលវិទ្យាធិការអាចទទួលប្រតិភូកម្មនៃអំណាចពីមន្ត្រីក្រសួង អប់រំជាតិ ក្នុងវិស័យគ្រប់គ្រងសកលវិទ្យាល័យឱ្យមានដំណើរការល្អ ។ សេចក្តីសំរេចទាំងឡាយរបស់ ប្រធាននៃសាកលវិទ្យាល័យនេះ គឺគាត់ធ្វើក្នុងនាមលោករដ្ឋមន្ត្រី ។ ប្រតិភូកម្មនៃអំណាចត្រូវ ធ្វើឱ្យអាជ្ញាធរថក្នាក្រោម ដោយមិនចំពោះបុគ្គលណាឡើយ គឺថាគេរំលែកអំណាចពីអង្គការមួយ ទៅឱ្យអង្គការមួយទៀត ពុំមែនពីបុគ្គលម្នាក់ ទៅឱ្យបុគ្គលម្នាក់ទៀតឡើយ គឺមិនដូចក្នុងនីតិឯកជនទេ ។ នៅក្នុងរបបវិសហមជ្ឈការ (deconcentration) គេអាចប្រគល់អំណាចឱ្យ ចុះហត្ថលេខា (delegation de signature) ។ ប៉ុន្តែ ខុសពីលិខិតប្រតិភូកម្មនៃអំណាចចុះហត្ថលេខា ត្រូវប្រគល់ឱ្យ ឈ្មោះបុគ្គល ហើយត្រូវធ្វើសារជាថ្មីបើមានការផ្លាស់ប្តូរបុគ្គល ។ អាជ្ញាធរថ្នាក់លើដែលបានផ្ទេរអំណាច ឬ ប្រគល់សិទ្ធិចុហៈត្ថលេខា មានសិទ្ធិត្រួតពិនិត្យគ្រប់យ៉ាងទាំងអស់ដែលគេហៅថា "សិទ្ធិអំណាចនាយ ចៅហ្វាយ" (pouvoir hierarchique)។

## ៣. សិទ្ធិនាយចៅហ្វាយ

- សិទ្ធិនេះ ជាសិទ្ធិដែលគេទទួលស្គាល់ឱ្យអាជ្ញាធរ អំណាចកណ្តាលដឹកនាំ និង ត្រួតត្រា ភ្នាក់ងារទាំងអស់ ដែលធ្វើការងារនៅក្នុងក្រសួង និង មន្ទីរនានាក្រោមឱវាទ ។
- ភ្នាក់ងារម្នាក់ៗ ជាអ្នកនៅក្រោមបង្គាប់ ចៅហ្វាយដែលនៅលើខ្លួន ជានាយចៅហ្វាយ របស់ភ្នាក់ងារ ឯទៀតៗដែលមានយសសក្តិទាបជាងខ្លួនផង ។
- សិទ្ធិ នាយចៅហ្វាយ អាចប្រព្រឹត្តទៅលើបុគ្គលផង និងទៅលើអំពើរបស់ភ្នាក់ងារផងៈ

### ក. លើបុគ្គលភ្នាក់ងារ

សិទ្ធិនាយចៅហ្វាយ គឺសិទ្ធិដាក់ពិន្ទុ ស្នើតំឡើងបុណ្យសក្តិ ចាត់តាំង ផ្លាស់ប្តូរ និង ដាក់ទណ្ឌ កម្មខាងវិន័យ ... ដល់បុគ្គលភ្នាក់ងារដែលនៅក្រោមឱវាទ ។

### ខ. លើកិច្ចការងារ

- អំណាចចេញបញ្ជាណែនាំ (Pouvoir dinstruction) អ្នកនៅក្រោមបង្គប់ផ្តាឱ្យបកបការងារ អ្វីមួយ តាមបំណងរបស់ខ្លួនព្រមទាំងសិទ្ធិត្រួតពិនិត្យកិច្ចការទាំងអស់ ដែលអ្នកក្រោមបង្គាប់ធ្វើ គឺមើល

ថាតើត្រូវ ឬ ខុសច្បាប់ ? ( Controle de legatlite ) តើសមតាមកាលៈទេសៈឬទេ? ( Controle de l′opportunité )

- អំណាចបដិសេធចោល ឬ កែប្រែ ( pouvir d′annilation ou de reformation ) អ្វីៗដែល អ្នកក្រោមបង្គាប់បានធ្វើដោយអត្តនោម័ត ។

- អំណាចធ្វើជំនួសអ្នកក្រោមបង្គាប់ ដោយផ្ទាល់តែម្តង ( pouvir de sudstitution ) ។ ប៉ុន្តែ សិទ្ធិនេះក៏មានព្រំដែនដែរ ។ ថៅហ្វាយត្រូវគោរពច្បាប់ដែលចែងអំពីលក្ខនត្តិៈ មន្ត្រីរាជការដោយ ពុំអាចបំពានបានឡើយ ។

- អ្នកក្រោមបង្គាប់អាចមិនគោរពបញ្ជា ដែលចេញមកខុសនិងច្បាប់យ៉ាងច្បាស់ក្រឡែត ហើយ ធ្វើអោយខូចប្រយោជន៍សាធារណៈ ។

- អ្នកក្រោមបង្គាប់ មិនប្តឹងតវ៉ាពីសេចក្តីសំរេចរបស់ថ្នាក់លើទេ លើកលែងតែមានការប៉ះពាល់លក្ខន្តិកៈ និង បុព្វសិទ្ធិរបស់ខ្លួន ។

## ៤. មណ្ឌលរដ្ឋបាល ( Circonseription Administrative )

ដើម្បីគ្រប់គ្រងទឹកដីនៃប្រទេសកម្ពុជាឱ្យគ្រប់ទីកន្លែងរដ្ឋត្រូវបែងចែកទឹកដីជាមណ្ឌលរដ្ឋបាលគឺត្រូវ រៀបចំព្រំប្រទល់ដែនដី សំរាប់ឱ្យរដ្ឋការប្រតិបត្តិការងាររបស់ខ្លួន បានយ៉ាងជាក់ស្តែង ។ មណ្ឌល រដ្ឋបាលជារង្វង់សមត្ថកិច្ចរបស់រដ្ឋបាបតាមតំបន់ ។ ក្នុងរបបមជ្ឈការសុទ្ធសាធ មានតែការបែងចែកទឹកដីជាមណ្ឌលរដ្ឋបាលប៉ុណ្ណោះ ។ បើមណ្ឌល រដ្ឋបាលណាមានទទួលពីអាជ្ញាធរកណ្តាលនូវអំណាចរំលែកខ្លះ មណ្ឌលនោះមានឈ្មោះហៅថា "មណ្ឌលរដ្ឋបាលវិសហមជ្ឈការ" (Circonseription Administrative Deconcentree ou Circonscription Deconcentree ) ។ មណ្ឌលរដ្ឋបាល គ្មានបុគ្គលភាពគតិយុត្តិេទពីព្រោះមិនមែនជានិតិបុគ្គលសាធារណៈ ។ កិច្ចការទាំង ឡាយដែលធ្វើក្នុងមណ្ឌលរដ្ឋបាល ជាកិច្ចការទាំងអស់េហើយធ្វើក្នុងនាមរដ្ឋ ។ រដ្ឋជានិតិបុគ្គលសាធារណៈតែមួយគត់ ក្នុងប្រទេសទាំងមូល ក្នុងរបបមជឈ្ឈារ ទោះបីមានវិមជ្ឈការក៏ដោយ ។ នៅប្រទេសបារាំងតំបន់ (Region) ខេត្ត (department) ស្រុក (Arrondissment) និង ឃុំ (Commune) ជាមណ្ឌលរដ្ឋបាលផង និងជាសមូហភាពដែនដីវិមជ្ឈការផង ។ ចំណែកឯ "កង់តុង" ចានតៀន គឺជាមណ្ឌលបោះឆ្នោតសំរាប់សមាជិកសភាខេត្ត (Conseillers generaux) មិនមែនជាមណ្ឌលរដ្ឋបាលទេ ។ មណ្ឌលបោះឆ្នោត ជាមណ្ឌលដែលកំណត់ឡើងតាមច្បាប់

បោះឆ្នោត គឺមិនមែនតាមច្បាប់គ្រប់គ្រងរដ្ឋបាលទេ ។ នៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ក្រុង ខេត្ត ស្រុក ខណ្ឌ ឃុំ និង សង្កាត់ សុទ្ធតែជាមណ្ឌលរដ្ឋបាល ទាំងអស់ ។ យើងគ្មាន "កង់តុង" ( canton ) ។

## ៥. មន្ទីរនានា ឬ សេវាក្រៅក្រសួង ( services exterieurs/external services)

គេហៅថា "មន្ទីរ" គឺជាស្ថាប័នរដ្ឋបាលមូលដ្ឋាន ឬ សាខារបស់ក្រសួងនានា នៅតាមខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ ។ ក្នុងរបបមជ្ឈការ មន្ទីខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវឡើងតាមខ្សែបណ្តោយមកអាជ្ញាធរកណ្តាល ដើម្បី សុំសំរេចអ្វីមួយ ។ ក្នុងរបបវិសហមជ្ឈការ មន្ទីការិយាល័យអាចទទួលបាននូវអំណាចបែងចែក គឺមានសិទ្ធិសំរេចតាម លក្ខខណ្ឌ ដែលក្រសួងបានកំនត់ឱ្យពីរាជធានីទៅ ១បារាំងគេហៅ {services deconcentres des ministeres} ។ ចំណែកប្រទេសកម្ពុជា តាមនយោបាយកំណែទំរង់ប្រព័ន្ធរដ្ឋបាលរាជរដ្ឋាភិបាលបានអនុវត្តវិសហមជ្ឈការដែនដីថ្នាក់ខេត្ត-ក្រុង និង វិសហមជ្ឈការបច្ចេកទេស ដើម្បីអមដំណើរនៃនយោបាយវិមជ្ឈការ ចំពោះវិសហមជ្ឈការ យើងមានឯកសារច្បាប់ដែលផ្តល់មូលដ្ឋានដល់វា ៖

- កម្មវិធីកែទំរង់រដ្ឋបាលសាធារណៈ ១៩៩៩-២០០៣ អនុម័តដោយរដ្ឋាភិបាលឆ្នាំ ១៩៩៨ ។
- ច្បាប់ចុះថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីទ្រព្យសម្បត្តិ និង ប្រព័ន្ធហិរញ្ញវត្ថុ ខេត្ត-ក្រុង ។

## ៦. ប្រព័ន្ធ ហិរញ្ញវត្ថុ ក្នុងរបបវិសហមជ្ឈការ (ករណីប្រទេសកម្ពុជា)

ប្រទេសកម្ពុជា បានត្រឡប់មកកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈមជ្ឈការព្រោះសុំណុំនៃប្រាក់ចំណូល និង ការចំណាយត្រូវកំណត់ និង អនុម័តក្នុងថវិកាជាតិ និង ត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យរបស់ក្រសួងហិរញ្ញវត្ថុ។[3] ខេត្តធ្វើសកម្មភាព ក្នុងនាមជាភ្នាក់ងាររបស់រដ្ឋបាលកណ្តាល អភិបាលខេត្តទទួលនូវប្រតិភូកម្មនៃអំណាចពីសំណាក់រដ្ឋមន្ត្រីនៃក្រសួងនានាសំរាប់គ្រប់គ្រងឥណទាន ដែលបានផ្តល់ទៅឱ្យមន្ទីរនានានៅក្នុងខេត្ត ។ រតនាគាជាតិដើរតួនាទីជាបេឡាធិការ និង គណៈនេយ្យករលើប្រតិបត្តិការលើថវិការជាតិ ។ ប្រព័ន្ធ ហិរញ្ញវត្ថុដែលមានលក្ខណមជ្ឈការ ត្រូវកែសំរួលដោយសារការផ្តល់សមត្ថភាព ខាងហិរញ្ញវត្ថុខេត្ត និង ការបញ្ចូលកម្មវិធីសកម្មភាពអាទិភាព (PAP = programme d'action prioritaire/ prority action program) របស់ក្រសួងដែលពាក់ព័ន្ធដល់ការងារសង្គម សុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍជនបទ សាធារណៈការ ។

[3] តាំងពីការអនុម័តច្បាប់ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការគ្រប់គ្រងថវិកាជាតិ។

## គ. ប្រព័ន្ធហិរញ្ញវត្ថុខេត្ត/ក្រុង ច្បាប់ថ្ងៃទី ២៨ កុម្ភៈ ១៩៩៨

តាមផ្លូវច្បាប់ខេត្ត និង ទទួលបាននូវលក្ខន្តិកៈជានិតិបុគ្គលសាធារណៈ ដែលមានសមត្ថកិច្ចត្រូវ កំណត់យ៉ាងច្បាស់លាស់ មានថវិកាផ្ទាល់ខ្លួនអភិបាលខេត្ត ជាអ្នកដឹកនាំរបស់ខេត្តជាមណ្ឌលរដ្ឋបាលស្វ័យ មួយ ហើយជាអ្នកតំណាងរបស់អំណាចកណ្តាល ស្ថិតនៅក្រោមអំណាចអាណាព្យាបាលរបស់រដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ សំរាប់ការងាររដ្ឋបាលសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ ការគ្រប់គ្រងហិរញ្ញវត្ថុខេត្ត ។ ហិរញ្ញវត្ថុខេត្ត/ក្រុងត្រូវបានគ្រប់គ្រងដោយគោលការណ៍ដូចតទៅៈ

- អភិបាលខេត្ត/ក្រុង ជាអ្នកតាក់តែងគំរោងថវិការបស់ខេត្ត/ក្រុង និងជាអ្នកអនុវត្តថវិកានេះ ។ សព្វថ្ងៃថវិកានេះ ត្រូវកំណត់សំរាប់ការចំណាយលើដំណើរការប្រចាំរបស់រដ្ឋបាលខេត្ត តែប៉ុណ្ណោះ ចំណែកការចំណាយនូវ តាមមន្ទីរនានាជាបន្ទុកថវិការរបស់ក្រសួងដែលពាក់ព័ន្ធ ។

- គំរោងថវិការបស់ខេត្ត ត្រូវយល់ព្រមដោយក្រសួងហិរញ្ញវត្ថុ ប្រមូលផ្តុំក្នុងកញ្ចប់ដែល និង ត្រូវអនុម័ត ដោយសភាជាតិ ក្នុងឱកាសអនុម័តថវិកាទូទៅរបស់រដ្ឋ ។

- ប្រភពថវិការបស់ខេត្ត-ក្រុង គឺបានពីចំណូលសារពើពន្ធដែលត្រូវកំណត់របស់ខេត្ត តាមច្បាប់ហិរញ្ញវត្ថុខេត្ត-ក្រុង ក្នុងឆ្នាំ ២០០០ ប្រភពចំណូលទាំងនេះមានកំរិតស្មើនិង ៥៥% នៃការចំណាយរបស់ខេត្ត ចំណែកដែលនៅសល់បានមកពីឧបត្ថម្ភរបស់ថវិកាជាតិ នាំអោយខេត្ត-ក្រុងមានលក្ខណៈរណប និង អំណាចកណ្តាល !!! ។

- ចំណូលសំរាប់ខេត្តត្រូវប្រមូលដោយភ្នាក់ងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុ ដែលមានទី តាំងនៅតាមខេត្ត/ក្រុង រតនាគារខេត្ត/ក្រុង បដែលជាអ្នកធានាការទូទាត់ និង គណនេយ្យ របស់ខេត្តផងដែរ ។

- ខេត្ត/ក្រុងគ្មានសិទ្ធិធ្វើកិច្ចសន្យាខ្ចីលុយបានទេ ឯកជន បរទេស ឬ អង្គការផ្សេងៗ ប៉ុន្តែ ច្បាប់ឆ្នាំ ១៩៩៨ បានផ្តល់ឱ្យវានូវសេរីភាពក្នុងការជ្រើសរើសបែបបទ ឬ ទំរង់នៃការគ្រប់ គ្រងសេវាសាធារណៈរបស់ខេត្ត រដ្ឋាករ សហគ្រាសសាធារណៈ សម្បទាន...ជាសរុប មកខេត្ត/ក្រុង នៅប្រទេសកម្ពុជាទទួលបានស្វ័យត ភាពផ្នែកហិរញ្ញវត្ថុដ៏មានកំរិត ខេត្ត/ក្រុង នៅតែខ្វះធនធានផ្ទាល់ខ្លួន ការចំណាយរបស់ខេត្ត/ក្រុង ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ យ៉ាងល្អិតល្អន់ ។ ខេត្ត/ក្រុងមិនមាន

ភាពម្ចាស់ការ ពិតប្រាកដទៅលើប្រាក់ចំណូល ដែលត្រូវ បាន ប្រគល់មកឱ្យខ្លួនទេ មូលដ្ឋានអត្រាព័ន្ធ និង ការប្រមូលព័ន្ធជា សមត្ថកិច្ចរបស់រដ្ឋបាល កណ្តាល ប ។

ម៉្យាងទៀតក្នុងថវិការបស់ខេត្តមិនមានការកំណត់ទុក ដោយឡែកសំរាប់ចំណាយមូលធនក្នុងពេល ដែលផ្តល់មូលនិធិមិនបានគ្រប់ទេ ។ ទោះបីយ៉ាងនោះក្តីក៏ប្រព័ន្ធរដ្ឋបាល បច្ចុប្បន្នបានទៅកាន់កំរិតមួយ នៃសហមជ្ឈការ ហិរញ្ញវត្ថុហើយដែរ ។ ប្រព័ន្ធនេះត្រូវបានពង្រឹង និង កែលំអឱ្យមានប្រសិទ្ធភាពបាន ។

- តាមរយៈការបង្កើតធនធានដែលត្រូវផ្ទេរទៅឱ្យខេត្ត រួមបញ្ចូលទាំងការបង្កើតប្រាក់ចំណូលផ្ទាល់របស់ខេត្តប ដើម្បីឱ្យខេត្តមានប្រសិទ្ធិភាពអនុវត្តការ វិនិយោគហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែង និង ផ្តល់នូវ សេវាសាធារណៈឱ្យកាន់តែប្រសើរ ។

- ការបញ្ជាក់បំភ្លឺពីតួនាទីរបស់ខេត្ត លើកធ្វើពីកម្មវិធីនិងការអនុវត្តគោលនយោបាយ ឬ សកម្ម ភាពដែលជាផលប្រយោជន៍របស់ខេត្តនិងការបន្ថយការត្រួតពិនិត្យផ្នែកថវិការបស់ ភ្នាក់ងារនៃ អំណាចកណ្តាល ។

### ខ. កម្មវិធីសំរាប់សកម្មភាពជាអាទិភាព ( programes d"action priortaire )

កម្មវិធីនេះ ( PAP ) គឺជាការផ្តួចផ្តើមអនុវត្តដោយក្រសួងសេដ្ឋកិច្ច និង ហិញវត្ថុ ដើម្បីផ្តល់ទៅឱ្យ ក្រសួងនានាដែលពាក់ព័ន្ធនិងការងារសង្គម សុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ សាធារណៈការនូវថវិកាដ៏ទូលាយ ជាពិសេសទាក់ទងដល់ប្រតិបត្តិការរបស់មន្ទីរនៅខេត្តនានា ដែលបានទទួល នៅប្រតិភូកម្មនៃសមត្ថកិច្ចពីក្រសួង ។ តាមពិត PAP គឺជាវិធានការ នៃទំរង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ PAP មានគោលដៅលើកកំពស់ ប្រសិទ្ធភាពនៃការចំណាយសាធារណៈ ដោយផ្អែកលើការធ្វើកម្មវិធីថវិកា ចំណាយ ។ យោងតាមស្មារតីនៃការកែទំរង់នេះ (PAP) ក្រសងួអទិភាពទាំងអស់និងត្រូវមានប្រសិទ្ធិធ្វើ ដោយខ្លួនឯងនូវគំរោងថវិការបស់គេ ក្រោមរូបភាពកម្មវិធីសកម្មភាពដែលត្រូវកំណត់យ៉ាងច្បាស់លាស់ និង មានគោលដៅពិតប្រាកដ ។

## ៧. អំពីវិមជ្ឈការ

វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានគេមើលឃើញថាជា កំណែទម្រង់ "ចេញពីឆន្ទៈ" ដែល រដ្ឋាភិបាលជាតិ ធ្វើការផ្ទេរអំណាច ជាដំណាក់ៗ ទាំងអំណាចហិរញ្ញវត្ថុ ឬអំណាចរដ្ឋបាល ទៅឱ្យ រដ្ឋបាលមូលដ្ឋាន

ដើម្បីគ្រប់គ្រងកិច្ចការក្នុងតំបន់របស់គេ។ កំណែទម្រង់តាមបែបប្រជាធិបតេយ្យនេះ បានចាប់ផ្ដើមឡើងពីរដ្ឋបាលដែនដីថ្នាក់ទាបបំផុត ឃុំ-សង្កាត់ ទៅរដ្ឋបាលដែនដីខ្ពស់បំផុត រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ។ វឌ្ឍនភាពនៃកំណែទម្រង់នេះ ត្រូវបានគូសបញ្ជាក់ជាមួយនឹង ការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅឆ្នាំ២០០៨។[4]

### ក. សញ្ញាណទូទៅនៃវិមជ្ឈការ

វិមជ្ឈការ ជាប្រព័ន្ធរដ្ឋបាលមួយ ដែលអនុញ្ញាតិអោយសមូហភាពដែនដី ឬ សេវាសាធារណៈ ធ្វើការគ្រប់គ្រងដោយខ្លួនឯង ក្នុងក្របខណ្ឌនៃការគោរពគោលការណ៍នីត្យានុកូលភាព ។ ប្រព័ន្ធនេះផ្ដល់ ទៅអោយសមូហភាពដែនដី ឬ សេវាសាធារណៈ នូវបុគ្គលិកលក្ខណៈគតិយុត្តសាធារណៈសយ្ភ័ាពរដ្ឋបាល និង ហិរញ្ញវត្ថុ ( Personnalité Jurdique Autonomie Administrative et Financiére/ Autonom Administrative Juridical Personality and Finance) ។ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាល ដែលរដ្ឋបាលកណ្ដាលផ្ទេរអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន (រដ្ឋបាលឃុំ-សង្កាត់) ។ ការផ្ទេរអំណាចបែបនេះ ក្នុងគោលបំណងឱ្យរដ្ឋបាលមូលដ្ឋាន ទទួលខុសត្រូវលើកិច្ចការណាដែលជាប្រយោជន៍របស់ខ្លួនផងដែរ ។ តាមន័យបច្ចេកទេសគតិយុត្ត វិមជ្ឈការ គឺជាការបង្កើតនីតិបុគ្គលដាច់ចេញពីរដ្ឋ ដែលមានសមត្ថកិច្ចផ្ទាល់ ពោលគឺនីតិបុគ្គលនេះ ប្រតិបត្តិនូវសមត្ថកិច្ចដោយរបៀបស្វយ័ត ។ បច្ចេកទេសនៃការគ្រប់គ្រងបែបវិមជ្ឈការ មានលក្ខណៈពិសេសបីគឺ៖

- បុគ្គលភាពគតិយុត្ត
- សមត្ថកិច្ចផ្ទាល់
- ការទទួលបានស្វ័យភាពកំណត់

រដ្ឋបាលវិមជ្ឈការ មានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ ពោលគឺអង្គការនេះ គឺជាប្រធាននៃនីតិផ្សេងពីរដ្ឋ ។ អង្គការនេះ មានសិទ្ធកាតព្វកិច្ច គោលដៅ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ បន្ថែមពីនេះទៀត រដ្ឋបាលវិមជ្ឈការ ទទួលបានសមត្ថកិច្ច ដែលកំណត់ដោយច្បាប់ ពោលគឺមានឯកភាពពីរដ្ឋ ដូច្នេះក្រោយពេលកំណត់សមត្ថកិច្ចឱ្យរដ្ឋបាលវិមជ្ឈការ រដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានទេ ។ ជាចុងក្រោយរដ្ឋបាលវិមជ្ឈ

[4] Joakim Öjendal & គិម សេដារ៉ា. "តើជាប្រជាធិបតេយ្យូបនីយកម្ម ពិតប្រាកដទេ? ការពិនិត្យលើបទ ពិសោធន៍អំពីសក្តានុពលនៃកំណែទម្រង់វិមជ្ឈការ." មជ្ឈមណ្ឌលអន្តរជាតិដើម្បីប្រជាធិបតេយ្យមូលដ្ឋាន (ICLD) ឯកសារលេខ ០៩ (ឆ្នាំ២០១១): ទំព័រ ១-២។ ចូលអាននៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១៥។

ការទទួលបានស្វ័យភាព ដែលធ្វើឱ្យខ្លួនមិនស្ថិតនៅក្នុងអំណាចឋានានុក្រម ។ ប៉ុន្តែ ជាតថភាពស្វ័យភាពនេះមិនឯករាជ្យទេដោយសារតែរដ្ឋបាលកណ្តាលនៅតែមានសិទ្ធប្រើអំណាចត្រួតពិនិត្យក្នុងនាមជាអាណាព្យាបាល ឬតាមរយៈស្ថាប័នតុលាការ ។ ជាការពិតប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការមានខ្លឹមសារជាការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ ជម្រុញឱ្យមានអភិបាលកិច្ចល្អ និងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយសាររដ្ឋអំណាចបានធ្វើការផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ ។ នៅក្នុងកាលានុវត្តភាពនេះ រដ្ឋអាចស្គាល់ និងជ្រួតជ្រាបអំពីការលំបាក ទុក្ខធុរៈ និងតម្រូវការរបស់ប្រជារាស្ត្រ ដែលជាហេតុធ្វើឱ្យរដ្ឋមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងកែលម្អនូវយុទ្ធសាស្ត្រដឹកនាំឱ្យកាន់តែមានប្រសិទ្ធភាព ។ ថ្វីត្បិតតែប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ មានប្រភពមកពីការធ្វើកំណែទម្រង់នៃប្រព័ន្ធរដ្ឋបាលបែបមជ្ឈការក្តី ក៏ប្រព័ន្ធវិមជ្ឈការនៅតែមានគុណវិបត្តិផងដែរនៅក្នុងការដឹកនាំប្រទេស ។

### ខ. គុណសម្បត្តិនៃវិមជ្ឈការ

- បើកទូលាយសិទ្ធិសេរីភាពឲ្យប្រជាពលរដ្ឋចូលរួមសហការក្នុងការងាររបស់រដ្ឋអំណាចកណ្តាល គឺរដ្ឋាភិបាលនេះឯង។
- អនុញ្ញាតឲ្យអាជ្ញាធរមូលដ្ឋានអាចចេញសេចក្តីសម្រេចផ្សេងៗ ឬលិខិតបទដ្ឋាននានាដោយឡែកសម្រាប់គ្រប់គ្រង និងអភិវឌ្ឍមូលដ្ឋាន។

### គ. គុណវិបត្តិនៃវិមជ្ឈការ

- ធ្វើឲ្យបាត់បង់ឯកភាពជាតិដោយសារតែការអនុវត្តន៍វិធានការរដ្ឋបាលខុសគ្នាពីខេត្ត ក្រុង មួយទៅខេត្ត ក្រុងមួយផ្សេងទៀត។
- ធ្វើឲ្យមានការប្រកួតប្រជែងគ្នាលើការអភិវឌ្ឍន៍រវាងមូលដ្ឋានមួយ ដែលជាហេតុនាំឲ្យប៉ះពាល់ដល់ប្រយោជន៍បុគ្គល ឬសមូហភាព។

## ៤. ភាពខុសគ្នារវាងវិមជ្ឈការ និង វិសហមជ្ឈការ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាល ប្រគល់នូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សា

រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។[5]

ឧទាហរណ៍៖

រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួន ៤០លានរៀល សម្រាប់ជាថវិការបស់រដ្ឋបាលស្រុកមួយក្នុងគោលដៅនៃការអភិវឌ្ឍ។ ក្រុមប្រឹក្សាស្រុកនោះមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្រុក ដោយផ្អែកតាមកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ស្រុក ដែលបានអនុម័តដោយក្រុមប្រឹក្សា ដូចជា សម្រាប់ជីអណ្តូងទឹកស្អាត ជួសជុលផ្លូវលំ និងផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍តាមតម្រូវការរបស់ប្រជាពលរដ្ឋជាដើម។ ក្នុងន័យនេះ ថវិកា៤០លានរៀល រដ្ឋាភិបាលបានផ្តល់នូវភាពជាម្ចាស់ក្នុងការគ្រប់គ្រងដល់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាមានភាពម្ចាស់ក្នុងការជ្រើសរើសគម្រោងមួយចំនួនដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយប្រើប្រាស់ថវិកានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ថវិកាទាំងនេះ ក្រុមប្រឹក្សាត្រូវតែអនុវត្តតាមនីតិវិធីដែលបានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានស្តីពីថវិកាស្រុក។

ចំណែកឯ វិសហមជ្ឈការ មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្ម មុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាភាពជាម្ចាស់នោះ។

ឧទាហរណ៍ ១៖

ក្រសួងកសិកម្ម ធ្វើប្រតិភូកម្មមុខងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មឲ្យទៅមន្ទីរកសិកម្មខេត្ត ព្រមទាំងផ្តល់ធនធាន និងបច្ចេកទេសឲ្យមន្ទីរកសិកម្មខេត្ត ដើម្បីផ្សព្វផ្សាយដល់ប្រជាកសិករនៅក្នុងខេត្តរបស់ខ្លួន។ មន្ទីរកសិកម្មខេត្តធ្វើការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម តាមការណែនាំរបស់ក្រសួងកសិកម្ម ក្នុងនាមជាតំណាងឲ្យក្រសួងកសិកម្ម។

[5] យោងតាមសៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបោះពុម្ពដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ឆ្នាំ ២០១០។

ឧទាហរណ៍ ២៖

ក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្មមុខងារធ្វើសេចក្តីចម្លងអត្រានុកូលដ្ឋាន ទៅឲ្យក្រុមប្រឹក្សាស្រុក ហើយអភិបាលស្រុកត្រូវបានប្រគល់ឲ្យអនុវត្តការងារនេះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ក្នុងការធ្វើប្រតិភូកម្មមុខងារនេះ ក្រសួងមហាផ្ទៃនឹងផ្តល់នូវធនធាន និងការបណ្តុះបណ្តាលសមត្ថភាព ដល់អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។ អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុក អនុវត្តការចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋក្នុងស្រុករបស់ខ្លួន តាមការណែនាំពីក្រសួងមហាផ្ទៃ និងក្នុងនាមក្រសួងមហាផ្ទៃ៕

## ៩. ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។
- ច្បាប់ស្តីពីការគ្រប់គ្រងថវិកាជាតិ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។
- ច្បាប់ស្តីពីទ្រព្យសម្បត្តិ និង ប្រព័ន្ធហិរញ្ញវត្ថុ ខេត្ត-ក្រុង ចុះថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ ១៩៩៨ ។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០២ និងឆ្នាំ២០០៨ ។
- ច្បាប់ចុះថ្ងៃទី ៦ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីរដ្ឋបាលដែនដីរបស់សាធារណៈរដ្ឋបារាំង និង ក្រឹត្យ ចុះថ្ងៃទី ១ កក្កដា ឆ្នាំ ១៩៩២ ស្តីពី ធម្មនុញ្ញនៃវិសហមជ្ឈការ។
- ព្រះរាជក្រឹត្យ លេខ នស/រកម/០៥០១/១៧៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០១។
- អនុក្រឹត្យ លេខ ៤៥៦ ស្តីពីការផ្ទេរធនធានពីថវិកាជាតិ ទៅមូលនិធិឃុំ-សង្កាត់ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៣។ អនុក្រឹត្យ លេខ ៣៤២ ស្តីពីការផ្ទេរធនធាន ពីថវិកាជាតិ ទៅមូលនិធិក្រុង-ស្រុក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤។
- កម្មវិធីកែទំរង់រដ្ឋបាលសាធារណៈ ១៩៩៩-២០០៣ អនុម័តដោយរដ្ឋាភិបាលឆ្នាំ ១៩៩៨ ។
- សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបោះពុម្ពដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ឆ្នាំ២០១០ ។